# សិក្ខាសាលាស្តីអំពី កម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន

នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គការ សេដាក បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំថ្នាក់ខេត្តមួយស្តីអំពី **កម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន** នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ អ្នកចូលរួមចំនួន ៩១ នាក់ ( ស្រ្តី ១៩នាក់) ដែលរួមមានស្ថាប័នរដ្ឋបាលមូលដ្ឋានថ្នាក់ខេត្ត ក្រុមសម្របសម្រួលខេត្ត ក្រុមសម្របសម្រួលថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ អ្នកគាំទ្រគម្រោងការអភិវឌ្ឍន៍ប្រជាធិបតេយ្យតាមរយៈ វិមជ្ឈការ និងវិសហមជ្ឈការ រតនាគារខេត្ត តំណាងអង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរស្រុក ខេត្ត និងបុគ្គលិកអង្គការ សេដាក បានអញ្ជើញចូលរួមក្នុងសិក្ខាសាលានេះ។ គោលបំនងនៃសិក្ខាសាលាគឺ ដើម្បីបង្ហាញអំពី ភាពរីកចំរើន និងការសម្រេចបានសំខាន់ៗរបស់កម្មវិធីនៅឆ្នាំ ២០០៨ ឆ្លុះបញ្ចាំងអំពីអ្វីដែលដំណើរការ និងមិនដំណើរការ និងមូលហេតុ និងដើម្បីស្វែងរកអនុសាស្រ្ត និងយុទ្ធសាស្រ្ត ដើម្បីការអភិវឌ្ឍន៍កម្មវិធី សម្រាប់ឆ្នាំ២០០៩ នេះ ។ អង្គសិក្ខាសាលាបានដំណើរទៅយ៉ាងរលូន ដែលអ្នកចូលរួមទាំងអស់មានឱកាសពិភាក្សានូវកង្វល់របស់ពួកគាត់ និងអំពីចំនុចដែលត្រូវកែលម្អជាដើម ។ល។ សិក្ខាសាលានេះទទួលបានការគាំទ្រពីភ្នាក់ងារអភិវឌ្ឍន៍អាមេរិក យូសេដ តាមរយៈអង្គការ ផែកកម្ពុជា។ ជាលទ្ធផលយើងទទួលបាននូវ មតិ យោបល់ និង អនុសាសន៍ល្អៗជាច្រើនសម្រាប់យកមកកែលម្អកម្មវិធីរបស់យើង ជាពិសេសទាក់ទងទៅនឹងរបៀបសហប្រ តិបត្តិការរវាងអ្នកពាក់ព័ន្ធទាំងឡាយនៅក្នុងគំរោង ។

# សិក្ខាសាលាថ្នាក់ខេត្ត ស្តីអំពីការឆ្លុះបញ្ចាំងប្រចាំឆ្នាំ

នៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០០៩ អង្គការ សេដាក បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំថ្នាក់ខេត្តមួយ ស្តីអំពីក**ម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន** នៅការិយាល័យអង្គការ សេដាក ខេត្តតាកែវ ។ អ្នកចូលរួម ចំនួន ១៥០ នាក់ ( ស្ត្រី ១៩ នាក់) ដែលរួមមានស្ថាប័នរដ្ឋបាលមូលដ្ឋានថ្នាក់ខេត្ត ក្រុមសម្របសម្រួលខេត្ត ក្រុមសម្របសម្រួលថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ អ្នកគាំទ្រគម្រោងការអភិវឌ្ឍន៍ប្រជាធិបតេយ្យតាមរយៈ វិមជ្ឈការ និងវិសហមជ្ឈការ រតនាគារខេត្ត តំណាងអង្គការក្រៅរដ្ឋាភិបាល អជ្ញាធរស្រុក ខេត្ត និងបុគ្គលិកអង្គការ សេដាក បានអញ្ជើញចូលរួមក្នុងសិក្ខាសាលានេះ។ គោលបំណងនៃសិក្ខាសាលាគឺដើម្បី :

- បង្ហាញអំពីភាពរីកចំរើន និង ការសម្រេចបានសំខាន់ៗរបស់កម្មវិធីនៅឆ្នាំ២០០៨
- ឆ្លុះបញ្ចាំងអំពីអ្វីដែលដំណើរការ និងមិនដំណើរការ ព្រមទាំងមូលហេតុ
- ស្វែងរកអនុសាស្ត្រ និងយុទ្ធសាស្ត្រ ដើម្បីការអភិវឌ្ឍន៍កម្មវិធីសម្រាប់ឆ្នាំ ២០០៩ នេះ

អង្គសិក្ខាសាលាបានដំណើរទៅយ៉ាងរលូន ដែលអ្នកចូលរួមទាំងអស់ មានឱកាសពិភាក្សានូវកង្វល់របស់ពួកគាត់ និងអំពីចំនុចដែលត្រូវកែលម្អជាដើម ។ល។ ជាលទ្ធផលយើងទទួលបាននូវមតិ យោបល់ និងអនុសាសន៍ល្អៗជាច្រើន សម្រាប់យកមកកែលម្អកម្មវិធីរបស់យើង ជាពិសេសទាក់ទងទៅនឹងរបៀប សហប្រតិបត្តិការរវាងអ្នកពាក់ព័ន្ធទាំងឡាយនៅក្នុងគំរោង ។